# បញ្ជីផ្ទៀងផ្ទាត់ដើម្បីដោះស្រាយករណីសិទ្ធិមនុស្ស

នៅក្នុងករណីសិទ្ធិមនុស្សមួយ ការអនុវត្តន៏សិទ្ធិមនុស្សមួយត្រូវបានប៉ះពាល់ដោយការអនុវត្តសិទ្ធិមនុស្សរបស់អ្នកដទៃ ឬក៏ដោយសារការដាក់កំហិតរបស់រដ្ឋាភិបាល ។

សំនួរខាងក្រោមនេះនាំអ្នកទៅរកករណីសិទ្ធិមនុស្សមួយ និងជួយអ្នកឱ្យរកឃើញនូវដំណោះស្រាយមួយផងដែរ ។

**១. តើមនុស្ស ឬស្ថាប័នដែលពាក់ព័ន្ធនៅក្នុងជម្លោះនោះជានរណា?**

**២. តើអ្វីទៅជាផលប្រយោជន៏ដែលមានវិវាទនឹងគ្នារបស់មនុស្ស និងស្ថាប័នទាំងនេះ ហើយតើវាមានទំនាក់ទំនងនឹងគ្នាយ៉ាងដូចម្តេច?**

**៣. ក. តើសិទ្ធិមនុស្សណាមួយដែលត្រូវបានប៉ះពាល់នោះ?**
**ខ. តើអ្វីទៅជាភារកិច្ចស្របច្បាប់ របស់ស្ថាបន័ដែលពាក់ព័ន្ធនោះ?**
(សូមមើលរដ្ឋធម្មនុញ្ញកម្ពុជា និង ICCPR ព្រមទាំងអនុសញ្ញាអន្តរជាតិដទៃទៀត)

**៤. តើពាក្យផ្សេងៗដែលបានចែងនៅក្នុងមាត្រាអំពីសិទ្ធិមនុស្សមានអត្ថន័យដូចម្តេច?**
(សូមមើលអ៊ិនធឺណែតអំពីការអធិប្បាយ សេចក្តីសម្រេច ដំណោះស្រាយ សេចក្តីថ្លែងការណ៏ និងការវិនិច្ឆ័យផ្សេងៗស្តីពីសិទ្ធិមនុស្ស និងប្រធានបទដែលពាក់ពន្ធ័ ដែលអ្នកអាចរកឃើញ)

**៥. តើមាត្រាអំពីសិទ្ធិមនុស្សអាចអនុវត្ត ចំពោះករណីជាក់លាក់មួយដែរឬទេ?**
(សូមពិនិត្យមាត្រានេះ ជាជំហានៗ និងមួយពាក្យម្តងៗ)

**៦. តើគេមានដាក់កំហិតអ្វីខ្លះ ទៅលើសិទ្ធិមនុស្សនេះ?**
(សូមមើលថាតើការដាក់កំហិតណាខ្លះដែលបានចែងនៅក្នុងមាត្រានៃរដ្ឋធម្មនុញ្ញកម្ពុជា និងICCPR)

**៧. តើមានច្បាប់ ពិសេសណាមួយដែលកំណត់នូវការដាក់កំហិតទៅលើសិទ្ធិមនុស្សដែរឬទេ?**
សូមរកមើលច្បាប់របស់កម្ពុជាដែលទាក់ទងនឹងប្រធានបទនេះ ។ សូមមើលសេចក្តីពិស្តារនៃច្បាប់នេះដែលពាក់ពន្ធ័នឹងវិធានការនៃការដាក់កំហិត ។ សូមអនុវត្តច្បាប់ទាំងនេះចំពោះករណីសិទ្ធិមនុស្ស ជាជំហានៗ និងមួយពាក្យម្តងៗ!

**៨. តើការដាក់កំហិតដែលគេយកមកប្រើនោះ វាសមាមាត្រឬទេ ឬក៏វាខ្លាំងពេក? (គោលការណ៏នៃភាពសមាមាត្រ)**
(តើវិធានការនៃការដាក់កំហិតទៅលើសិទ្ធិមនុស្សរបស់មនុស្សម្នាក់ វាសមស្របទៅនឹងគោលបំណង ដើម្បីការពារសិទ្ធិដទៃទៀតឬទេ? តើគោលបំណងនេះអាចសំរេចបានដោយប្រើវិធានការធូរស្រាលជាងនេះឬទេ?

ដោយធ្វើការឆ្លើយនឹងសំណួរទាំងប្រាំបីមួយម្តងៗ សំណួរជាមូលដ្ឋានមាន បី ដែលត្រូវឆ្លើយ:

- តើសិទ្ធិមនុស្សដែលពាក់ព័ន្ធនោះមានទំហំប៉ុណ្ណា?
- តើសិទ្ធិមនុស្សអាចត្រូវគេដាក់កំហិត ដើម្បីការពារសិទ្ធិមនុស្សមួយទៀតដែរឬទេ?
- តើការដាក់កំហិតនោះវាពិតជាចាំបាច់(សមាមាត្រ) ឬទេ ដើម្បីការពារសិទ្ធិមនុស្សមួយទៀតនោះ?

## សិទ្ធិមនុស្ស និងការដាក់កំហិត

<table>
<tr><td>តើខ្ញុំអាចរកឃើញ<br>សិទ្ធិមនុស្សនៅឯណា?</td><td>នៅក្នុង<br>អនុសញ្ញាអន្តរជាតិ<br>- UDHR (ពីមាត្រា ១ - ២៨)<br>ប្រយ័ត្ន: UDHR ពុំមែនជាចំណងចំពោះរដ្ឋទាំងនោះទេ<br>- ICCPR (ពីមាត្រា ៦-២៧)<br>- CESCR (ពីមាត្រា ៦-១៥)<br>- CERD (មាត្រា ៥)<br>- CEDAW (ពីមាត្រា ១-១៦)<br>- CAT (ពីមាត្រា ១-១៦)<br>- CRC (ពីមាត្រា ១-៤១)</td><td>នៅក្នុង<br>រដ្ឋធម្មនុញ្ញកម្ពុជា<br>ពីមាត្រា ៣១-៥០</td></tr>
<tr><td>តើខ្ញុំអាចរកឃើញ<br>ការដាក់កំហិតលើសិទ្ធិមនុស្សនៅឯណា?</td><td>នៅក្នុង<br>អនុសញ្ញាអន្តរជាតិ<br>មើលខាងលើ<br>(ឧទាហរណ៍: មាត្រា ៩ I ២, ១២ III, ១៨ III, ១៩III,២១ I ២ ICCPR)</td><td>នៅក្នុង<br>រដ្ឋធម្មនុញ្ញកម្ពុជា<br>ពីមាត្រា ៣១-៥០<br>(ឧទាហរណ៍: មាត្រា ៣១ II ២, ៤១ I ២,៤៣ II,៤៤ III CC)</td></tr>
<tr><td colspan="3">អ្នកធ្វើច្បាប់កម្ពុជាដែលត្រូវអនុញ្ញាតឱ្យបញ្ញត្តិការដាក់កំហិតលើសិទ្ធិមនុស្ស ត្រូវធ្វើដូច្នេះ ដោយបង្កើតច្បាប់ធម្មតា</td></tr>
<tr><td>តើខ្ញុំអាចរកវិធានពិស្តារស្តីពីការដាក់កំហិត<br>នៅឯណា?</td><td colspan="2">នៅក្នុង<br>ច្បាប់កម្ពុជានានាដែលអនុម័តដោយសភាជាតិ<br>ឧទាហរណ៍: ក្រមព្រហ្មទណ្ឌអន្តរកាល, ច្បាប់ស្តីពីបាតុកម្ម, ច្បាប់សារពត៌មាន, ច្បាប់ភូមិបាល, ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។ល។<br><br>(ប៉ុន្តែមិនមែននៅក្នុងប្រកាស, អនុក្រឹត្យ ឬបទបញ្ជារដ្ឋបាលផ្សេងទៀតនោះទេ ព្រោះការដាក់កំហិតលើសិទ្ធិមនុស្សអាចត្រូវបានចែងនៅក្នុងច្បាប់តែមួយគត់! អាជ្ញាធរ គ្រាន់តែត្រូវអនុវត្តច្បាប់ទាំងនោះ និងអាចបញ្ញត្តិបទបញ្ជានៅក្នុងករណីពិសេសមួយប៉ុណ្ណោះ ។)</td></tr>
</table>

## ? សំនួរសិក្សាទី៦

នៅឆ្នាំ២០០២ ហាងខារ៉ាអូខេទាំងអស់ត្រូវបិទទ្វារដោយសារបទបញ្ជាមួយ និង ត្រូវតែបិទក្នុងរយៈពេលខ្លីបំផុត ។

ក. តើអ្នកណាខ្លះជាភាគីពាក់ព័ន្ធនៅក្នុងរឿងនេះ?

ខ. សូមរៀបរាប់ និង ពន្យល់អំពីផលប្រយោជន៍ប្រកួតប្រជែងរបស់ភាគីនីមួយៗ ។
សូមបញ្ជាក់អំពីបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធផង:

គ. តើបទបញ្ជាឱ្យបិទហាងខារ៉ាអូខេទាំងអស់នោះស្របទៅនឹង "គោលការណ៍នៃភាពសមាមាត្រ" ដែរឬទេ? សូមពន្យល់អំពីយោបល់ផ្នែកច្បាប់របស់អ្នក ។

## ? សំនួរសិក្សាទី៧

បន្ទាប់ពីមានកុបកម្មប្រឆាំងនឹងថៃនាថ្ងៃទី២៩ មករា ២០០៣ អាជ្ញាធរបាននិយាយថា "យើងមិនអាចបញ្ឈប់បាតុករដែលប្រើអំពើហិង្សាបានទេ ពីព្រោះយើងមានជំរើសតែពីរ: មួយឱ្យពួកគេធ្វើ ឬមួយបាញ់ពួកគេ" ។
ចូរអានច្បាប់ស្តីពីបាតុកម្មដែលមានភ្ជាប់ជាមួយនេះ ។
តើមានជំរើសតែពីរសំរាប់អាជ្ញាធរមែនឬ?
តើមានវិធានការផ្សេងៗអ្វីខ្លះ ដែលច្បាប់ស្តីពីបាតុកម្មចែងអំពីបាតុកម្មដោយហិង្សា? (ចូរកុំភ្លេចដកស្រង់មាត្រាច្បាប់ច្បាស់ៗដែលពាក់ព័ន្ធ) ។

## ? សំនួរសិក្សាទី៨

សំណុំរឿង:

ប៉ូលិសចាប់ខ្លួនមនុស្សម្នាក់ក្នុងចំណោមបុរសជាច្រើនដែលបានរំលោភស្ត្រីម្នាក់ ។ នៅក្នុងពន្ធនាគារ ពួកគេសួរគាត់ឱ្យប្រាប់ពីឈ្មោះជនល្មើសផ្សេងទៀត ប៉ុន្តែគាត់បដិសេធមិនប្រាប់ឈ្មោះអ្នកទាំងនោះទេ ។ ប៉ូលិសវាយគាត់ជាច្រើនលើក ដើម្បីចង់ដឹងឈ្មោះមិត្តភក្តិរបស់គាត់ ។
អ្នកទោសដែលត្រូវគេវាយដំបានទំនាក់ទំនងជាមួយមេធាវីរបស់ខ្លួន និងសុំឱ្យមេធាវីប្តឹងអំពីការធ្វើមិនគួរគប្បីរបស់អាជ្ញាធរ ។

តើបណ្តឹងរបស់គាត់ត្រឹមត្រូវដែរឬទេ?
សូមពិនិត្យសំណួរ ដោយឆ្លើយម្តងមួយៗ នូវសំណួរនីមួយៗក្នុងបញ្ជីផ្ទៀងផ្ទាត់!